# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៧២០ អយក.ជាវ

ថ្ងៃអង្គារ ៦កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**ជម្រាបជូន**

**-ឯកឧត្តម លោកជំទាវ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ**
**-ឯកឧត្តម លោកជំទាវ សាកលវិទ្យាធិការ នាយកវិទ្យាស្ថាន**
**-ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទទីស្តីការក្រសួង**

កម្មវត្ថុ ៖ សំណើសុំផ្តល់ផែនការសកម្មភាពអាទិភាពក្នុងវិស័យអប់រំ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨ និងកញ្ចប់ថវិកាប្រចាំឆ្នាំ២០២៦។

យោង ៖ សារាចរលេខ០០១ សហវ.ស.រ.អថ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជ្រាបថា៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញនូវសារាចរលេខ០០១ សហវ.ស.រ.អថ ស្តីពីប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៥ ក្នុងគោលបំណងប្រមូលធាតុចូលសំខាន់ៗដូចជា គោលនយោបាយថ្មី និងកត្តាជំរុញតម្រូវការ សម្រាប់ជាមូលដ្ឋាននៃការរៀបចំក្របខណ្ឌថវិការយៈពេលមធ្យម ឱ្យមានភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ។ ក្នុងន័យនេះ ដើម្បីឱ្យមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការជជែកពិភាក្សាជាមួយមន្ត្រីបច្ចេកទេសរបស់អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការបញ្ចូលសកម្មភាពអាទិភាពទៅក្នុងពិតានចំណាយគោល សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨និងកញ្ចប់ថវិកាប្រចាំឆ្នាំ២០២៦ខាងមុខ ហើយធ្វើយ៉ាងណាឱ្យសង្គតិភាពទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០២៤-២០២៨ និងកម្មវិធីកំណែទម្រង់វិស័យអប់រំ។ ដូចនេះ ក្រសួងស្នើសុំ**ឯកឧត្តម លោកជំទាវ លោក លោកស្រី** ប្រធានអង្គភាព ពិនិត្យនិងផ្តល់សកម្មភាពអាទិភាពបំផុតរបស់អង្គភាពសាមីសម្រាប់បញ្ចូលក្នុងគម្រោងថវិកាឆ្នាំ២០២៦ រួចបញ្ជូនមកនាយកដ្ឋានហិរញ្ញវត្ថុយ៉ាងយូរត្រឹមថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៥ ខាងមុខ។

- សូមជូនភ្ជាប់នូវតារាងរៀបចំផែនការសកម្មភាពអាទិភាពនិងតម្រូវការវិនិយោគថវិកាឆ្នាំ២០២៦។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** មេត្តាជ្រាប និងចាត់ចែងឱ្យមានប្រសិទ្ធភាពខ្ពស់និងទាន់ពេលវេលា តាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី**ប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**រដ្ឋលេខាធិការ**

**អ៊ុង បូរាត**

**ចម្លងជូន៖**
-អគ្គលេខាធិការដ្ឋាន
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
"ដើម្បីជូនជ្រាបជាព័ត៌មាន"
-កាលប្បវត្តិ
-ឯកសារ នាយកដ្ឋានហិរញ្ញវត្ថុ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋាន.....

# ផែនការសកម្មភាពសម្រាប់ការគ្រោងថវិកាឆ្នាំ២០២៦

ឯកតា៖ លានរៀល

| ល.រ | មុខសញ្ញាចំណាយ | តម្រូវការតំណទាន | បរិយាយ/ពន្យល់ | ផ្សារភ្ជាប់សូចនាករក្នុង ESP | ផ្សារភ្ជាប់កំណែទម្រង់របស់ក្រសួង | ផ្សេងៗ |
|---|---|---|---|---|---|---|
| | សរុប | | | | | |
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |
| ១០ | | | | | | |
| ១១ | | | | | | |

បានឃើញ និងឯកភាព
ប្រធានកម្មវិធី

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋាន

ថ្ងៃ ខែ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៥
អ្នកធ្វើតារាង